## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៧ . សរណន**

# សារាចរណែនាំ
## ស្តីពី
## ការកំណត់លក្ខខណ្ឌ នៃការផ្ទេរក្របខ័ណ្ឌមន្ត្រីដែលមិនស្ថិតនៅក្រោម ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ទៅបំរើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

បច្ចុប្បន្ន រាជរដ្ឋាភិបាលពិនិត្យឃើញថា មានការស្នើសុំផ្ទេរមន្ត្រីដែលមិនស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលទៅបំរើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលកាន់តែមានចំនួនច្រើនឡើងៗ។ ចំពោះមុខដើម្បីពង្រឹងការអនុវត្តន៍ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនីមួយៗ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗក៏ដូចជាការរក្សាគុណសម្បត្តិមន្ត្រីឱ្យបានឯកភាពគ្នាក្នុងក្របខ័ណ្ឌតាមលក្ខន្តិកៈដោយឡែកនីមួយៗ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចខាងក្រោម :

- មន្ត្រីទាំងឡាយដែលមិនស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាដែលទទួលបានការតែងតាំងឱ្យបំពេញមុខងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលត្រូវរក្សាទុកក្របខ័ណ្ឌ និងបៀវត្សនៅអង្គភាពដើម ហើយទទួលប្រាក់បំណាច់មុខងារនៅក្នុងរដ្ឋបាលស៊ីវិលទៅតាមមុខតំណែងដូចមន្ត្រីរាជការស៊ីវិលទូទៅដែរ ហើយនៅពេលដែលចប់មុខតំណែងនៅក្នុងរដ្ឋបាលស៊ីវិល ត្រូវវិលត្រឡប់ទៅអង្គភាពដើមវិញ។
- មន្ត្រីទាំងឡាយដែលមិនស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងបំរើការងារក្នុងរដ្ឋបាលស៊ីវិល អាចផ្ទេរក្របខ័ណ្ឌមកក្របខ័ណ្ឌរដ្ឋបាលស៊ីវិលបានលុះត្រាតែបានទទួលការបណ្តុះបណ្តាល ឬវគ្គវិក្រឹត្យការពីសាលាភូមិន្ទរដ្ឋបាលជាមុនសិន។

ទទួលបានសារាចរណែនាំនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**